# ធម្មទេសនារបស់លោកអភិបាលអូលីវីយេ
# អភិបូជាអគ្គសញ្ញាលាបថ្ងាស
# ពោធិ៍ធំ ថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១៩
# អ្នកណាស្រឡាញ់ខ្ញុំអ្នកនោះនឹងប្រតិបត្តិតាមពាក្យខ្ញុំ

**អត្ថបទទី១៖ កិច្ចការ ១៥,១-២.២២-២៩**

ព្រះវិញ្ញាណដ៏វិសុទ្ធ* និងយើងខ្ញុំយល់ឃើញថា មិនគួរយកវិន័យ*ណាផ្សេងទៀតដែលមិនចាំបាច់ មកបង្ខំបងប្អូនឲ្យប្រតិបត្តិតាមឡើយ។ កក ១៥,២៨

**អត្ថបទទី២៖ វិវរណៈ ២១,១០-១៤.២២-២៣**

ក្រុងនេះប្រកបដោយសិរីរុងរឿងរបស់ព្រះជាម្ចាស់ ពន្លឺរស្មីរបស់ក្រុងប្រៀបបីដូចជាត្បូងដ៏មានតម្លៃបំផុត គឺដូចត្បូងមណីជោតិរសដែលភ្លឺថ្លាដូចកែវចរណៃ។ វវ២១,១១

**ដំណឹងល្អ៖ យ៉ូហាន ១៤,២៣-២៩**

ព្រះយេស៊ូមានព្រះបន្ទូលទៅគាត់ថា៖ «អ្នកណាស្រឡាញ់ខ្ញុំអ្នកនោះនឹងប្រតិបត្តិតាមពាក្យខ្ញុំ។ ព្រះបិតាខ្ញុំនឹងស្រឡាញ់អ្នកនោះ ហើយព្រះបិតា និងខ្ញុំ ក៏នឹងមកតាំងលំនៅ នៅក្នុងអ្នកនោះដែរ។ យហ ១៤,២៣

បងប្អូនជាទីស្រឡាញ់!

ថ្ងៃនេះ យើងមានកូនជាង៣០នាក់ដែលទទួលអគ្គសញ្ញាលាបថ្ងាស មានន័យថាទទួលព្រះវិញ្ញាណដ៏វិសុទ្ធ ទទួលជង្រើម កម្លាំង សេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់។ ជាពេលវេលាមួយ ដើម្បីឲ្យយើងពិចារណា **តើអនាគតយើងចង់ធ្វើអ្វី?** ក្នុងព្រះគម្ពីរដំណឹងល្អព្រះជាម្ចាស់មានព្រះបន្ទូលថា "**សូមបង្កើតកូនយ៉ាងច្រើននិងសូមថែរក្សាផែនដី**"។ ថ្ងៃនេះ ព្រះវិញ្ញាណដ៏វិសុទ្ធយាងមកសណ្ឋិតលើយើងទាំងអស់គ្នា យើងមានសំណួរបីដើម្បីពិចារណា គឺ៖

ទីមួយ **តើយើងចង់សាងសង់ព្រះសហគមន៍របស់ព្រះគ្រីស្តនៅប្រទេសកម្ពុជារបៀបណា?** យើងជាគ្រីស្តបរិស័ទតើយើងចង់សាងសង់ព្រះសហគមន៍របស់យើងដូចម្តេច?

ទីពីរ **តើខ្ញុំចង់សាងសង់សង្គមរបៀបណា?** យើងជាជនជាតិខ្មែរ រស់នៅលើទឹកដីកម្ពុជា តើយើងចង់ឲ្យសង្គមរបស់យើង ទៅជាសង្គមរបៀបណា?

ទីបី **តើខ្ញុំផ្ទាល់ខ្លួនខ្ញុំចង់កសាងជីវិតខ្ញុំដូចម្តេច?** ខ្ញុំចង់ធ្វើជាមនុស្សដូចម្តេច ខ្ញុំត្រូវការធ្វើអ្វីខ្លះដើម្បីឲ្យទាំងសង្គម ទាំងព្រះសហគមន៍ ទាំងជីវិតរបស់ខ្ញុំអាចទៅមុខនៅក្នុងគម្រោងការដ៏អស្ចារ្យរបស់ព្រះជាម្ចាស់។

កន្លែងនេះជាកន្លែងពិសេស ខ្ញុំធ្លាប់បានស្តាប់យាយៗដែលផ្តល់សក្ខីភាពអំពីមរណសាក្សី ដែលមានលោកអភិបាល ឆ្មារ សាឡាស់ លោកឪពុក ឆ្មារ សាឡឹម។ លោកឪពុក សាឡឹម ជាអ្នកទទួលខុសត្រូវព្រះសហគមន៍នេះ រហូតដល់ខ្មែរក្រហមចូលនៅក្នុងទីក្រុងភ្នំពេញ។ យាយៗនិយាយថា លោកឪពុកគាត់មកថ្វាយអភិបូជាបុណ្យចម្លងនៅថ្ងៃទី៣០ ខែមីនា ឆ្នាំ១៩៧៥ ពីរអាទិត្យមុនខ្មែរក្រហមចូលក្នុងទីក្រុងភ្នំពេញ។ លោកថា ជារាត្រីបុណ្យចម្លងឲ្យយើងរៀបចំជប់លៀងមួយនៅក្នុងអំណរសប្បាយ ហើយមានលោកយាយម្នាក់និយាយទៅកាន់លោកឪពុកថា តើយើងធ្វើពិធីពោរពេញដោយអំណរសប្បាយយ៉ាងមិចកើត ដោយដឹងថាយើងកំពុងចូលនៅក្នុងសង្គ្រាម យើងនៅក្នុងទុក្ខលំបាកមែនទែន។ លោកឪពុក ឆ្មារ សាឡឹម ថានៅទីនេះយើងគោរពព្រះយេស៊ូមានព្រះជន្មរស់ឡើងវិញ ទោះបីនៅជុំវិញយើងមានទុក្ខលំបាក មានសង្គ្រាមដែលកំពុងកើតឡើង យើងជាគ្រីស្តបរិស័ទយើងត្រូវតែជប់លៀងដើម្បីបង្ហាញអំណរសប្បាយនៃជំនឿរបស់យើង។

**ព្រះសហគមន៍ដែលយើងចង់សាងសង់** នៅទីនេះជាទឹកដីមរណសាក្សីរបស់យើង ជាទឹកដីមួយយ៉ាងពិសេស ដែលព្រះសហគមន៍ភូមិភាគភ្នំពេញបានកើតឡើង ១៥០ឆ្នាំមុន។ ជាកន្លែងដែលយើងទទួលបេសកកម្មដើម្បីបន្តឲ្យព្រះសហគមន៍របស់យើងមានជីវិត ដើម្បីបន្តឲ្យព្រះសហគមន៍របស់យើងរស់នៅតាមព្រះបន្ទូលរបស់ព្រះជាម្ចាស់។ នៅក្នុងសម័យខ្មែរក្រហម យើងមិនហ៊ានបង្ហាញអំពីជំនឿរបស់យើង ដូចក្នុងកិច្ចការគ្រីស្តទូតថ្ងៃនេះគេភ័យ មានគេសម្លាប់ព្រះយេស៊ូហើយ។ ក្នុងសម័យខ្មែរក្រហម យើងមិនហ៊ានថ្វាយអភិបូជា មិនហ៊ានអប់រំជំនឿ យើងមិនហ៊ានជួបជុំជាគ្រីស្តបរិស័ទ ប៉ុន្តែនៅពេលនេះជាជីវិតថ្មីរបស់យើង។ យើងពោរពេញដោយព្រះវិញ្ញាណដ៏វិសុទ្ធដូចក្រុមគ្រីស្តទូត នៅពេលក្រុមគ្រីស្តទូតបានទទួលព្រះវិញ្ញាណដ៏វិសុទ្ធ គេបានចេញតាមផ្លូវ គេលែងភ័យខ្លាច គេបន្តប្រកាសអំពីព្រះយេស៊ូមានព្រះជន្មរស់ឡើងវិញថ្ងៃនេះ។ គេបានទៅប្រកាសដំណឹងល្អ ដើម្បីឲ្យមនុស្សយ៉ាងច្រើនរស់នៅក្នុងជីវិតថ្មីនិងអំណរសប្បាយរបស់ព្រះជាម្ចាស់។ ដូច្នេះព្រះសហគមន៍ដែលយើងចង់បង្កើត ជាព្រះសហគមន៍ដែលពោរពេញដោយអំណរ ជាព្រះសហគមន៍ដែលពោរពេញដោយសេចក្តីសុខសាន្ត ជាព្រះសហគមន៍ដែលផ្តល់សក្ខីភាពអំពីភាតរភាពយ៉ាងពិតប្រាកដ។ មិនចេះមើលងាយគ្នាទៅវិញទៅមក ចេះទទួលស្គាល់ថាបងប្អូនទាំងអស់ជាបុត្រាបុត្រីរបស់ព្រះជាម្ចាស់នៅក្នុងមហាគ្រួសារតែមួយ។ គម្ពីរដំណឹងល្អ "**អ្នកណាស្រឡាញ់ខ្ញុំ អ្នកនោះស្រឡាញ់ព្រះបិតា អ្នកណាស្រឡាញ់ខ្ញុំ អ្នកនោះប្រតិបត្តិតាមព្រះបន្ទូលរបស់ខ្ញុំ**" ព្រះសហគមន៍ដែលយើងចង់បង្កើត ជាព្រះសហគមន៍មួយដែលអនុវត្តព្រះបន្ទូលរបស់ព្រះយេស៊ូ គឺ "**ស្រឡាញ់គ្នាទៅវិញទៅមកដូចខ្ញុំបានស្រឡាញ់អ្នក**

**រាល់គ្នា**" មិនមែនស្រឡាញ់គ្នាធម្មតា គឺស្រឡាញ់គ្នាតាមរបៀបព្រះយេស៊ូដែលបានស្រឡាញ់យើង។ ព្រះសហគមន៍ដែលយើងចង់បង្កើត ជាព្រះសហគមន៍មួយដែលចេះអធិដ្ឋាន ដែលស្តាប់ព្រះបន្ទូលរបស់ព្រះយេស៊ូ ដើម្បីអនុវត្តព្រះបន្ទូលនេះជាប្រចាំនៅក្នុងជីវិតផ្ទាល់ខ្លួន។

**សង្គមដែលយើងចង់បង្កើត** យើងមើលនៅក្បែររង្វង់មូលសម្តេចសង្ឃរាជ្យ ឈួន ណាត យើងឃើញមានពុទ្ធសាសនបណ្ឌិត ក្រសួងធម្មការ និងសាសនា រដ្ឋសភាជាតិ ណាហ្កា...។ ប្រទេសយើងជាប្រទេសគោរពជាតិ សាសនា ព្រះមហាក្សត្រ ជាតិយើងមានរដ្ឋសភា សាសនាយើងមានពុទ្ធសាសនបណ្ឌិត ព្រះមហាក្សត្រដែលគង់នៅព្រះរាជ្យវាំង។ ប៉ុន្តែនៅជាប់នឹងពុទ្ធសាសនបណ្ឌិតយើងមានណាហ្កាដែលជាកន្លែងលេងល្បែង លាងលុយ ដែលណែនាំឲ្យមានបញ្ហានៅក្នុងគ្រួសារ សង្គម តើយើងធ្វើដូចម្តេចដើម្បីកសាងប្រទេសរបស់យើង? សម្រាប់យើងដែលពោរពេញដោយកម្លាំង តើយើងចង់កសាងប្រទេសយើងដូចម្តេច? យើងមិនមែនជាអ្នកដឹកនាំប្រទេស តែយើងអាចទៅរកផ្លូវមួយដើម្បីចូលនៅក្នុងសង្គមយ៉ាងពិសេស ឲ្យការងាររបស់យើង វត្តមានរបស់យើង អាចបង្កើតទំនាក់ទំនងជាមួយមនុស្សទាំងអស់ និងរស់នៅក្នុងចិត្តស្មោះត្រង់ សេចក្តីស្រឡាញ់ និងយុត្តិធម៌។ តើយើងធ្វើដូចម្តេច ដើម្បីធ្វើជាពលរដ្ឋដែលពោរពេញដោយយុត្តិធម៌ ធ្វើជាពលរដ្ឋសុចរិតដែលចេះបង្កើតទំនាក់ទំនងជាមួយសង្គម ដែលចេះមើលអ្នកតូចតាចដែលគ្មានអ្វីសោះ ដែលចេះបង្កើតទំនាក់ទំនងជាមួយអ្នកមានដើម្បីឲ្យរួមគ្នាយើងអាចកសាងមហាគ្រួសារនៃប្រទេសកម្ពុជា។

**ជីវិតដែលត្រូវកសាង** យើងជាមនុស្សសកម្ម ឬមនុស្សខ្ជិល ឬមនុស្សក្បាលរឹង ថ្ងៃនេះព្រះយេស៊ូមានព្រះពន្ទូលថា "**ខ្ញុំទុកសេចក្តីសុខសាន្តឲ្យអ្នករាល់គ្នា ខ្ញុំផ្តល់សេចក្តីសុខសាន្តរបស់ខ្ញុំឲ្យអ្នករាល់គ្នា ថ្ងៃនេះខ្ញុំចង់ឲ្យបងប្អូនពោរពេញដោយអំណរសប្បាយ ប្រសិនបើអ្នករាល់គ្នាស្រឡាញ់ខ្ញុំអ្នករាល់គ្នាមុខតែសប្បាយចិត្ត ថ្ងៃនេះខ្ញុំចង់ឲ្យបងប្អូនចេះស្រឡាញ់គ្នា អ្នកណាស្រឡាញ់ខ្ញុំអ្នកនោះនឹងប្រតិបត្តិតាមពាក្យខ្ញុំ**" សេចក្តីស្រឡាញ់ សេចក្តីសុខសាន្តនិងអំណរសប្បាយនេះជាគម្រោងការនៃជីវិតរបស់យើង។ យើងត្រូវធ្វើជាមនុស្សដែលមានតុល្យភាព មនុស្សដែលចេះរស់នៅក្នុងសង្គមជាគ្រីស្តបរិស័ទពិតប្រាកដ ដែលចេះស្រឡាញ់ ដែលចេះគោរព ជាពិសេសដែលទទួលសេចក្តីសុខសាន្តពីព្រះជាម្ចាស់ និងចេះបង្កើតបរិយាកាសនៃសេចក្តីសុខនៅកន្លែងដែលយើងនៅ។ យុវជនយុវនារី ជាសញ្ញាសម្គាល់នៃជីវិតព្រះសហគមន៍របស់យើង ពេលយើងទទួលអគ្គសញ្ញាលាបថ្ងាសថ្ងៃនេះជាកម្លាំងថ្មីនៅក្នុងព្រះសហគមន៍របស់យើង។ ជីវិតមិនមែនដោយសារអាគារ ជីវិតមិនមែនដោយសារវិហារដែលយើងមាន គឺជីវិតដោយសារបងប្អូនទាំងអស់ ដែលចេះស្រឡាញ់និងប្រតិបត្តិតាមព្រះបន្ទូលរបស់ព្រះយេស៊ូ។ អាម៉ែន៕